# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តបាត់ដំបង**
**លេខ:**..........................

## សេចក្តីបំភ្លឺព័ត៌មាន

**រដ្ឋបាលខេត្តបាត់ដំបង** មានកិត្តិយស សូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋ និងសាធារណជនមេត្តាជ្រាបថា កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ មានការផ្សព្វផ្សាយ និងចែករំលែកព័ត៌មានតាមបណ្តាញសង្គម និងគេហទំព័រសារព័ត៌មានផ្សេងៗ ពាក់ព័ន្ធនឹងករណីទឹកស្ទឹងសង្កែមានពណ៌ខ្មៅខុសប្រក្រតី និងមានការពុលងាប់ត្រីមួយចំនួន។ **រដ្ឋបាលខេត្តបាត់ដំបង** សូមធ្វើការបំភ្លឺដូចតទៅ៖ ក្រោយពីទទួលបានព័ត៌មាននេះភ្លាម គណៈកម្មការចម្រុះខេត្ត បានចុះទៅពិនិត្យ និងស្រាវជ្រាវដល់ទីតាំងជាក់ស្តែងរយៈពេលពីរថ្ងៃមកហើយ ដោយបានរកឃើញថា ទឹកដែលមានពណ៌ខ្មៅខុសប្រក្រតីខាងលើ បានបង្កឡើងពីសំណល់រាវរបស់រោងចក្រមួយកន្លែង ហូរចូលក្នុងទឹកស្ទឹងសង្កែ ដែលមានទីតាំងស្ថិតនៅភូមិក្វាវ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។ ជាមួយគ្នានេះ រដ្ឋបាលខេត្តបានណែនាំឱ្យ មន្ត្រីបច្ចេកទេសរដ្ឋាករទឹកបាត់ដំបង នៃមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្ត ធ្វើការពិនិត្យ និងបានរកឃើញថា ទឹកនៅតែរក្សាបានគុណភាពល្អជាធម្មតាអនុលោមតាមស្តង់ដារគុណភាពទឹកស្អាត និងមិនមានផលប៉ះពាល់ដល់សុខភាពឡើយ ហើយបច្ចុប្បន្នទឹកស្ទឹងសង្កែបានវិលត្រឡប់មកសភាពដើមជាធម្មតា។ ទន្ទឹមនេះ រដ្ឋបាលខេត្តបានចាត់វិធានការចំពោះក្រុមហ៊ុន ដោយបានធ្វើកិច្ចសន្យា និងមិនអនុញ្ញាតឱ្យមានការហូរចេញនូវសំណល់រាវ (ទឹកកខ្វក់) សំណល់រឹង និងសារធាតុពុល ឬសារធាតុគីមីគ្រប់ប្រភេទ ចេញពីទីតាំងរោងចក្រចូលទៅក្នុងទឹកស្ទឹងសង្កែ សារជាថ្មីម្តងទៀតទេ។ បើករណីនេះនៅតែបន្តកើតមានឡើង ក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់។

ចំពោះមុខ រដ្ឋបាលខេត្ត បានគោរពស្នើសុំកិច្ចអន្តរាគមន៍បន្ថែមទៀតពី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីមានវិធានការណ៍ផ្អាករោងចក្រ មិនឱ្យដំណើរការជាបណ្តោះអាសន្ន និងស្នើសុំទៅក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ ដើម្បីពិនិត្យ និងវាយតម្លៃផលប៉ះពាល់បរិស្ថានសារឡើងវិញ ជៀសវាងបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពបងប្អូនប្រជាពលរដ្ឋនៅពេលក្រោយទៀត។

អាស្រ័យហេតុនេះសូមបងប្អូនប្រជាពលរដ្ឋ និងសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
បាត់ដំបង ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៣
**រដ្ឋបាលខេត្តបាត់ដំបង**

អាសយដ្ឋាន: ផ្លូវលេខ០១, ទល់មុខស្ពានថ្មចាស់, ទូរស័ព្ទ និងទូរសារលេខ: ០៥៣ ៧៣៩ ៩៩៩/ ៧៣៩ ៩៩៩ គេហទំព័រ: www.battambang.gov.kh
Address : Road 01, In front of old bridge, Telephone & Fax : 053 739 999 / 739 999 Website: www.battambang.gov.kh
អ៊ីម៉ែល / Email: info@battambang.gov.kh Facebook Page : រដ្ឋបាលខេត្តបាត់ដំបង: www.facebook.com/battambang.gov.kh